# តន្ត្រីប្រជាប្រិយនៅកម្ពុជា

តន្ត្រីបស្ចិមប្រទេស បានបញ្ជ្រាបចូលមកប្រទេសកម្ពុជាជាដំបូងបង្អស់នៅក្នុងអំឡុងសតវត្សទី១៦ជាមួយនឹងចលនាជំនួញគ្រឿងទេសព័រទុយហ្កេនៅអាស៊ី។ ម្យ៉ាងវិញទៀត កំណត់ត្រាប្រវត្តិសាស្ត្រត្រឹមតែចង្អុលទៅលើវត្តមានរបស់ជនជាតិអឺរ៉ុប និងតន្ត្រីវណ្ណកម្មបស្ចិមប្រទេស រួមទាំងតន្ត្រីត្រែឬគ្រឿងផ្លុំ តន្ត្រីសម្លេងស្រាល និងតន្ត្រីស៊ីមហ្វូនីនៅក្នុងអំឡុងសតវត្សទី២០តែប៉ុណ្ណោះ។ ក្រោយមកទៀត នៅក្នុងអំឡុងទសវត្សឆ្នាំ១៩៥០ ស្របជាមួយនឹងការបង្កើតសាលាជាតិផ្នែកតូរ្យតន្ត្រី តន្ត្រីករ តន្ត្រីការិនីខ្មែរក៏មានឱកាសបានរៀនតន្ត្រីវណ្ណកម្មបស្ចិមប្រទេស។

ដោយឡែក តន្ត្រីប្រជាប្រិយនិងការរាំបស្ចិមប្រទេស ត្រូវបានឧទ្ទេសនាមទៅតន្ត្រីករ តន្ត្រីការិនីនិងអ្នករាំខ្មែរដោយគ្រូហ្វីលីពីននិងបារាំង។ នៅអំឡុងដើមឆ្នាំ១៩០០ ព្រះបរមរាជវាំងខ្មែរ បានទទួលវង់តន្ត្រីខ្លាតធំមួយពីប្រទេសហ្វីលីពីនមកនៅក្នុងព្រះបរមរាជវាំង។ តន្ត្រីករហ្វីលីពីន បានបង្រៀនវង់តន្ត្រីព្យូហយាត្រា ឬហ្វង់ហ្វារនៅក្នុងព្រះបរមរាជវាំង ព្រមទាំងលេងភ្លេងនៅក្នុងវង្គនានាផង។ ដូច្នេះនៅពេលនោះ មានអ្នកខ្លះហៅភ្លេងប្រភេទនោះថា « ភ្លេងម៉ានីល»។

តន្ត្រីបស្ចិមប្រទេស ក៏បានផ្សព្វផ្សាយដោយសាស្ត្រាចារ្យបារាំងដែលបង្រៀននៅវិទ្យាល័យនាទីក្រុងភ្នំពេញ ហើយនៅក្នុងវិទ្យាស្ថានយោធា មន្ត្រីជាន់ខ្ពស់ខ្មែរក៏បានទទួល ការហ្វឹកហ្វឺនពីរបៀបរាំបស្ចិមប្រទេសដែរ។ ឧទាហរណ៍ ចង្វាក់ម៉ាឌីហ្សុន មានប្រជាប្រិយភាពណាស់នៅក្នុងទសវត្សឆ្នាំ១៩៥០។ ចំណែកឯចង្វាក់ទ្វីសវិញ ក៏មានប្រជាប្រិយភាពដែរ ក្រោយពីបានឧទ្ទេសនាមដោយលោក ជុំ កែម បន្ទាប់ពីលោកបានវិលត្រឡប់មកពីប្រទេសបារាំងវិញនៅដើមទសវត្សឆ្នាំ១៩៦០។[៦] ទោះជាយ៉ាងណាក៏ដោយ ចង្វាក់ខ្មែរ មានរាំវង់ រាំក្បាច់ សារ៉ាវ៉ាន់ ឡាំលាវ កន្ទ្រឹម តាលុង ប្រើន និងចូកគំពីស ក៏មានប្រជាប្រិយភាពខ្លាំង

[៦] Chen et al. 1993: 67

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ណាស់ដែរនៅពេលនោះ។ លោក វ៉ែន ផាត (ស្លាប់) ដែលជាព្រឹទ្ធបុរសមហាវិទ្យាល័យតូរ្យតន្ត្រីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានមានប្រសាន៍ថា គ្រូតន្ត្រីមកពីប្រទេសហ្វីលីពីនបានមកបង្ហាត់ក្រុមតន្ត្រីហ្វង់ហ្វារនៅក្នុងព្រះបរមរាជវាំងនាទីក្រុងភ្នំពេញ និងលេងក្លេងនៅក្នុងវង្គសាលមួយចំនួននៅកម្ពុជា។ តន្ត្រីករហ្វីលីពីន ក៏បានឧទ្ទេសនាមចង្វាក់ឡាតាំង (Latin rhythms) មាន ឆាឆាឆា បូឡេរ៉ូ តង់ហ្គោ បូសាណូវ៉ា និងរុមបា ព្រមទាំងចង្វាក់មួយចំនួនទៀត ដូចជា រ៉ក់ ហ្វុក រ៉ុកអ៊ែនរ៉ុល ម៉ាឌីហ្សុន និងទ្វីស ជាដើម។ល។[២]

ភាពល្បូតលាស់និងអភិវឌ្ឍន៍នៃតន្ត្រីប្រជាប្រិយនៅកម្ពុជា នៅក្នុងទសវត្ស១៩៥០ មានឥទ្ធិពលខ្លាំងពីប្រព័ន្ធការពារនិយម (Protectionism) ពីសំណាក់បុគ្គលមួយចំនួនតូចដែលគ្រប់គ្រងនិងត្រួតត្រាវិស័យតន្ត្រីប្រជាប្រិយនៅកម្ពុជា មានលោក ហាស់ សាឡុន មៃ ប៊ុន ពៅ ស៊ីផូ និងវ៉ោយ ហូ។ អ្នកចម្រៀងល្បីៗនាសម័យនោះ មានលោកស៊ិន ស៊ីសាមុត, សុះ ម៉ាត់, អ៊ិន យ៉េង, មាស ហុកសេង, អុំ សុងសឺង, ឱុច គឹមហាក់, អ៊ឹង ណារី, តូច តេង, លីវ តឹក, ទូច សាលី, ពៅ វណ្ណារី, មាស សាម៉ន, ហួរ ឡាវី, វ៉ៃ សារុន, តាន់ ក្ដុម្ពី, លី សុងឡេង, អ្នកនាងរស់ សេរីសុទ្ធា, ប៉ែនរ៉ន, ម៉ៅ សារ៉េត, សូ សាវឿន, ហួយ មាស, ឈុន វណ្ណា ឈួន, ម៉ាឡៃ សៀង, ឌី សៀង, វ៉ាន់ធី, សេងបទុម, និងតារា ចោមចន្ទ ជាដើម។ល។

អ្នកជំនាន់ក្រោយឆ្នាំ១៩៧៩ មានលោកព្រាប សុវត្ថិ, ណុប បាយ៉ារិទ្ធ, សាពូន មីដាដា, ឆន សុវណ្ណរាជ, ខេមរៈសេរីមន្ត, ខេម, គង់ សុធារិទ្ធ, ខាន់ ជេម, ម៉ៅ ហាជី, ដួង វីរៈសិទ្ធិ, ហេង ប៊ុនលាប, ណូយ វ៉ាន់ណេត, ណូយ វណ្ណា, នូ ស៊ឹប, ឡោ សារិត, ប៊ុន ចាន់ថន, សួស សងវាចា, អ៊ុក នារិន, ពេជ្រ ពន្លឺ, ឯក ស៊ីដេ, អៀង ស៊ីធុល, ម៉េង ប៊ុនលី, ឈឿន ឧត្ដម, អ៊ាន វិន, កែវ សារ៉ាត់, គង់ សូឌីណា, ឈួយ សូភាព, អ្នកនាងម៉េង កែវពេជ្ជតា, ម៉េង កែវពេជ្របុប្ផា, ហ៊ឹម ស៊ីវន, ទូច ស៊ុននិច, ខាត់ សុឃីម, គឹម លក្ខិណា, ស៊ុន ស្រីពេជ្រ, សួន ចន្ថា, កែវ កន្សា, ឱក សុគន្ធកញ្ញា, សុគន្ធ នីសា, មាស សុខសោភា, យក់ បិតរដ្ឋា, សឿ សុធាវ៉ា, សុខ ស៊ីឡាលីន,

[២] សម្ភាសន៍ជាមួយនឹងលោក វ៉ែន ផាត

អឿន ស្រីមុំ, បាន មុន្នីល័ក្ខណ៍, ពេជ្រ ចរិយា និងគ្រួសារអ្នកចម្រៀងត្រកូលឆោម ឆោម ឆវិន ឆោម ឆពង្ស ឆោម ប៊ុនយ៉ុង ជាដើម។ល។

**អ្នកនិពន្ធ**

ស៊ិន ស៊ីសាមុត, ម៉ម បុប្ផានី, មៃ ប៊ុន, ហ៊ិន មេឌីត, ពៅ ស៊ីផូ, វ៉ោយ ហូ, ម៉ៅ វណ្ណា, ប៉ិច សាលឿន, គង្គ ប៊ុនឈឿន, ម៉ក់ ឈួន, ហេង ហួរ៉េង, មាស គក, ម៉ា ឡៅពី, ជុំ កែម, យិន ឌីកាន, យ៉ង់ ឈៀង (សំនៀងវិទ្ធី), មិត្រ សាខុន, កែវ ឯម, អ៊ំ ដារា, ម៉ាក់ ថោង, ជិត ញ៉ែម, ថុន (ហៅកុក), សំ សាខន, ឯល ប៊ុនណា, អួម អួន, ម៉ុក ចាន់ម៉ាលី, ស្វាយ សំអឿ, អ៊ុយ ហ៊ែល, សាង សារ៉ាត, គឹម សំអែល, វ៉ោយ ហូ, វ៉ែន ផាត, ឯល ប៊ុណ្ណា, សុទ្ធី សួង, ពុទ្រា ប៊ិន, ដេវីដ (ប៊ិន ហុងផាត), មិញ សុធីវណ្ណ, មាស សុគន្ធ, សំ សំអាង, អ៊ូ ប៊ុនជួក, ហៃ្វ សំអាង, និងសុខ ជំនោរ។ល។

**ក្រុមតន្ត្រី**

ក្រុមតន្ត្រីល្បីៗនាទសវត្សឆ្នាំ១៩៦០និង១៩៧០មាន ក្រុមតន្ត្រីវិទ្យុជាតិ យោធាភិរម្យ អប្សរា បក្សីចាំក្រុង អេសកាដេ (SKD) និង Drakkar។ល។

**ផលិតកម្មតន្ត្រី**

នៅក្នុងអំឡុងទសវត្សឆ្នាំ១៩៦០និង១៩៧០ មាននៅតែក្នុងទីក្រុងភ្នំពេញ កម្ពុជាមានតែផលិតកម្មតន្ត្រីមួយចំនួនតូចតែប៉ុណ្ណោះមាន ចន្ទឆាយា ហេងហេង វ៉ាន់ចន្ទ វត្តភ្នំ ចាបមាស និងនគររាជ្យ។ល។ នាបច្ចុប្បន្ន យើងមានផលិតកម្មមួយចំនួនថែមទៀតដូចជាផលិតកម្មឆ្លងដែន រស្មីតាន់តាន់ Rock ហង្សមាស ថោន SK រស្មីស្ទឹងសង្កែ និងអង្គរវត្ត។ល។

នៅក្នុងវិស័យតន្ត្រីប្រជាប្រិយនេះ ព្រះមហាក្សត្រខ្មែរ ព្រះបាទសម្តេចព្រះបរមរតនកោដ្ឋក៏ព្រះអង្គទ្រង់ក្រសាលតន្ត្រីប្រជាប្រិយផ្ទាល់ព្រះអង្គដែរ ព្រមទាំងព្រះអង្គម្ចាស់ នរោត្តមសិរីវុឌ្ឍ និងអ្នកអង្គម្ចាស់ប៉ាណាវ៉ាសេរីវុឌ្ឍផង។ ព្រះបរមរតនកោដ្ឋ ទ្រង់បានផលិតភាពយន្តជាច្រើនរឿង ដែលមានបញ្ចូលឈុតតន្ត្រីនិងចម្រៀងប្រជាប្រិយ។ ស្នាព្រហស្តចម្រៀងប្រជាប្រិយរបស់ព្រះអង្គ មានចងក្រងបោះពុម្ពជាសៀវភៅចម្រៀង *Norodom Sihanouk: Musique et Chansons*។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

រហូតមកទល់នឹងពេលនេះ ខ្មែរយើងចាត់ទុកលោកស៊ិន ស៊ីសាមុត ជាអ្នកចម្រៀងខ្មែរម្នាក់ដែលមានកិត្តិនាមល្បីល្បាញជាងគេ ប្រកបដោយសំឡេងដ៏ពីរោះផ្អែមរណ្ដំទាក់ទាញមនោសញ្ចេតនានិងអារម្មណ៍អ្នកស្ដាប់គ្រប់គ្នា ដែលគេបានប្រសិទ្ធនាមថា «អធិរាជសំឡេងមាស»។ ដោយសារសំឡេងដ៏ពីរោះនិងភាពល្បីល្បាញរបស់លោកស៊ិន ស៊ីសាមុត ចម្រៀងរបស់លោកត្រូវបានគេយកមកលេង ចម្រៀងបន្ត និងផលិតឡើងវិញដើម្បីនឹងផ្សព្វផ្សាយនិងដាក់លក់ពាសពេញទីផ្សារនៅកម្ពុជានិងបរទេស។ បទមួយចំនួន គេបានបន្ថែមឧបករណ៍តន្ត្រីខ្លះនិងធ្វើគុណភាពសូរឲ្យកាន់តែប្រសើរឡើង។ លើសពីនេះទៅទៀត គេបានយកបទរបស់លោកទៅដាក់ជាមួយនឹងពាក្យពេចន៍ខ្លឹមសារដែលគេសរសេរថ្មី។

តន្ត្រីករប្រជាប្រិយខ្មែរ ក៏បានយកបទបរទេសមួយចំនួនមកលេងជាមួយនឹងពាក្យពេចន៍ខ្លឹមសារខ្មែរ ដូចជាបទ To Love Somebody, I Started a Joke, Imagine, Let It Be, Black Magic Woman, Oye Como Va, Corason Espinado, Rhythm of the Rain, Sealed with a Kiss, More than I Can Say, Bengawan Solo, Aline, Love Me និងបទមកពីភាពយន្ត «ទីតានិក» ជាដើម។ល។

នៅក្នុងអំឡុងពេលប្រមាណបីទសវត្សរ៍ក្រោយនេះ រង្គសាលនិងអាហារដ្ឋានជាច្រើនក្នុងបណ្ដាខេត្តក្រុងក៏ដូចជានៅតាមជនបទនៃប្រទេសកម្ពុជា បានរៀបចំឱ្យមានវង់តន្ត្រីប្រជាប្រិយលេងកំដរភ្ញៀវជាការកែកម្សាន្តផងដែរ។

ឯកសារដែលពាក់ព័ន្ធនឹងតន្ត្រីប្រជាប្រិយនៅកម្ពុជា មានតិចតួចណាស់ហើយភាគច្រើនផ្តោតទៅលើតែស្ថានភាពបច្ចុប្បន្ន និងតារាចម្រៀងល្បីៗដែលបានស្លាប់ទៅហើយ ដូចជាលោកស៊ិន ស៊ីសាមុតនិងអ្នកនាងរស់ សេរីសុទ្ធា ជាដើម។ អត្ថបទខ្លីដែលខ្ញុំសរសេរនៅទីនេះ មានគោលបំណងបំពេញនូវព័ត៌មានបន្ថែមខ្លះទៅលើអ្វីដែលយើងមានរួចមកហើយ។ ប្រសិនបើចង់ជ្រាបពីព័ត៌មានលម្អិត សូមអញ្ជើញអាននិងមើល សំ សំអាង (២០១៧); John Pirozzi, *Cambodia's Lost Rock & Roll*។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



## ឯកសារពិគ្រោះ

ចាប ពិន. (១៩៦៤). *របាំប្រជាប្រិយខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ប៊ុត បូរ. (១៦ កុម្ភៈ-១ មីនា ២០០៧). «ប្រវត្តិករីមែ ប៊ុន» *ទស្សនាវដ្ដី តារា*, ទំព័រ២២។

Chen, Vivian, et al. (1993). "Sharing Common Ground: Social Dancing in the USA" *1993 Festival of American Folklife*. Washington, DC: Smithsonian Institution, 63-68.

Norodom, Sihanouk. *Norodom Sihanouk: Musique et Chansons*. Phnom Penh: Royal Palace.

Pirozzi, John. *Cambodia's Lost Rock & Roll*. A film documentary.

*Rasmey Kampuchea, Vol. 3*. (2001). SM Productions, Cambodia.

Sam, Sam-Ang. (1990). *Patriotic and Traditional Khmer Songs*. Cambodian Business Corporation International PTKS90-SS-NT001, U.S.A.

________. (1999). *Hang Khnhomm-Saum Bang Vill Vinh*. Sen Monorom Productions SMP NCD001, U.S.A.

________. (2001). *Spean Yol. Amarin-Rangsey* Productions ARP NCD001, U.S.A.

________. (2017). "Cambodia," *Bloomsbury Encyclopedia of Popular Music of the World.* Bloomsbury: Bloomsbury Encyclopedia of Popular Music of the World.

Sar, Rumanea. (October 2000). "Peou Sipho: A Song Writer," *Popular Magazine*, p. 22.

Thoeung, Son. (1999). *Samut Moha Alai, #300*. Chlangden Productions, U.S.A.

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង